**សកម្មភាព** ៖ **ល្បែងផ្លាស់ប្តូរទីកន្លែង**

**ចិត្តចលភាព**

បំណិនចលកតូច (ការហ្វឹកហាត់បង្កើនកម្លាំង សម្របសម្រួលសាច់ដុំដៃ និងភ្នែកសាច់ដុំភ្នែក)។

បំណិនចលកធំ (ការហ្វឹកហាត់បង្កើនកម្លាំង សម្របសម្រួលសាច់ដុំតូច និងសាច់ដុំធំ)។

**បុរេគណិត**

ទំហំ និងពណ៌ (ចំណាត់ក្រុម និងលំដាប់លំដោយ)។

**គោលបំណង** ៖

**(ចិត្តចលភាព)** ប្រាប់ពីររបៀបធ្វើចលនាដៃតាមទម្រង់ផ្សេងៗដោយការធ្វើអ្វីមួយ ឬលេងល្បែង។ បង្ហាញពីរបៀបធ្វើសកម្មភាពទៅតាមទម្រង់ផ្សេងៗនៃសកម្មភាពរួមមួយ។

**(បុរេគណិត)** ប្រាប់បានពីរបៀបរៀបវត្ថុតាមលំដាប់ក្រុម ប្រភេទ ទំហំ និងពណ៌។

**កម្រិតសិក្សា** ៖ ទាប មធ្យម ខ្ពស់។

**សៀវភៅ** ៖ ដកស្រង់ចេញពីរឿង “តើនរណាជាអ្នកលាបពណ៌មេឃ?”

**រយៈពេល** ៖ ៣០ នាទី

**ឧបករណ៍** ៖ កាតពណ៌តូច

**ការរៀបចំ** ៖ធ្វើកាតពណ៌ឱ្យបានគ្រប់គ្រាន់ដើម្បីចែកក្មេងៗ ។

**សេចក្តីណែនាំ៖**

1. ថ្ងៃនេះអ្នកគ្រូនឹងលេង**ល្បែងផ្លាស់ប្តូរទីកន្លែង**ជាមួយកូនៗទាំងអស់គ្នា។
2. បែងចែកឱ្យក្មេងៗទាំងអស់ឈរ ឬអង្គុយជារង្វង់ក៏បាន។
3. ជ្រើសក្មេងម្នាក់ឱ្យអង្គុយចំកណ្តាលរង្វង់។
4. ចែកកាតពណ៌ដែលបានរៀបចំរួចនោះទៅកាន់ក្មេងៗ ។
5. ក្មេងៗចាំបាច់មានពណ៌ដូចគ្នា មិនមែនម្នាក់មួយពណ៌ទេ។
   ឧទាហរណ៍៖ កាតពណ៌ក្រហម ៤នាក់ ពណ៌លឿង ៤នាក់ ពណ៌ខៀវ ៤នាក់..។
   ប្រសិនបើនៅក្នុងថ្នាក់មានកន្លែងតូច មិនត្រូវប្រើប្រាស់កាតពណ៌ទាំងអស់នោះទេ។
6. ណែនាំក្មេងៗថាត្រូវចងចាំពណ៌ដែលខ្លួនគេកំពុងកាន់។
7. អ្នកអង្គុយចាំទីកណ្តាលរង់ត្រូវនិយាយថា “ខ្ញុំចូលចិត្តពណ៌ក្រហម” ឬ “ពណ៌ក្រហម”
8. ក្មេងៗដែលមានពណ៌ក្រហមទាំងប៉ុន្មាននាក់ចាំត្រូវផ្លាស់ប្តូរទីកន្លែងគ្នាអង្គុយ។
9. ហើយអ្នកដែលនៅចំកណ្តាលរង់នោះត្រូវស្វែងរកអ្នកដែលកន្លែងអង្គុយកន្លែងដដែល។
10. អ្នកដែលអង្គុយកន្លែងដដែលនឹងត្រូវចាញ់ ហើយមកចាំទីម្តង។




11. អ្នកគ្រូធ្វើដូចនេះ ដដែលរហូតដល់អស់ម៉ោងលេងហ្គេមនេះជាការស្រេច។


